# ពិធីការសម្រាប់ការរក្សាគម្លាតសង្គម៖
# ឧបសម្ព័ន្ធ A

**បច្ចុប្បន្នភាពថ្មីៗ៖** (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)
**3/5/2021៖**
- បន្ថែមភាសាដែលទាក់ទងនឹងការពិនិត្យតាមដានសម្រាប់និយោជិត និងអ្នកទស្សនានៅតាមទីតាំង ហើយក៏ ផ្លាស់ប្តូរពាក្យពី "ការគ្របមុខ" ទៅជាការប្រើ "របាំងមុខ" ។

**ឈ្មោះអាជីវកម្ម៖** ______________________________

**អាសយដ្ឋានទីកន្លែង៖** ______________________________

**ចំនួនមនុស្សអតិបរមា តាមច្បាប់អគ្គីភ័យ៖** ______________________________

**ប្រហាក់ប្រហែលទំហំទីធ្លាគិតសរុបជាហ្វីតការ៉េដែលបើកដល់សាធារណជន៖** ______________________________

**គ្រប់ស្ថាប័នទាំងអស់ត្រូវគ្រប់គ្រងដោយប្រើពិធីការនេះ និងត្រូវតែអនុវត្តវិធានការណ៍ជាធរមានទាំងអស់ ដែលមានរាយខាងក្រោមនេះ និងត្រូវត្រៀមខ្លួនពន្យល់ពីមូលហេតុក្នុងករណីដែលវិធានការណ៍ណាមួយ ដែលមិនត្រូវបានអនុវត្ត ថាមិនអាចអនុវត្តបានសម្រាប់ស្ថាប័ន ឬទីកន្លែង។**

នៅក្នុងពិធីសារដែលអនុវត្តតាមអត្ថន័យនៃពាក្យ "នៅក្នុងគ្រួសារ" គឺមានន័យថា "មនុស្សដែលរស់នៅជាមួយគ្នាក្រោមដំបូលតែមួយ" ហើយមិនត្រូវរាប់បញ្ចូលទាំងស្ថានភាពរស់នៅក្រុមរួមស្ថាប័ន ដូចជាអន្តេវាសិកដ្ឋាន ក្រុមធ្វើការរួមគ្នា សហគមន៍និស្សិតស្រី វត្តអារាម សន្និបាត ឬអគារថែទាំលំនៅដ្ឋានឡើយ។ ហើយក៏មិនរួមបញ្ចូលទាំង ការរស់នៅបែបពាណិជ្ជកម្ម ដូចជាផ្ទះសមាគមន៍ សណ្ឋាគារ ឬផ្ទះសំណាក់[1]នោះដែរ។ ពាក្យ" បុគ្គលិក" និង" និយោជិត" មានន័យរួមបញ្ចូលដូចជា និយោជិត អ្នកស្ម័គ្រចិត្ត អ្នកហាត់ការ និងសក្ខាកាម និស្សិត និងបុគ្គលដទៃទៀតដែលបំពេញការងារនៅកន្លែងរួមគ្នា។ ពាក្យ "អ្នកទស្សនា" ឬ "អតិថិជន" គួរតែត្រូវបានរាប់បញ្ចូលទាំងសមាជិកសាធារណៈ និងអ្នកផ្សេងទៀតដែលមិនមែនជាបុគ្គលិក ឬនិយោជិកដែលចំណាយពេលនៅតាមអាជីវកម្ម ឬ ទីតាំងនោះដោយផ្ទាល់។ ពាក្យ "ទីតាំង" និង "កន្លែង" សំដៅលើអាគារដី និងអាគារ ឬទីតាំងនៅជាប់គ្នាហើយមានសកម្មភាពផ្សេងៗ។

---

[1] Los Angeles County Code, Title 22. §22.14.060 - F. Family definition. (Ord. 2019-0004 § 1, 2019.) https://library.municode.com/ca/los_angeles_county/codes/code_of_ordinances?nodeId=TIT22PLZO_DIV2DE_CH22.14DE_22.14.060F.

## A. វិធានការណ៍ដើម្បីការពារសុខភាពបុគ្គលិក (គូសធីកចំណុចទាំងអស់ដែលត្រូវអនុវត្ត)

- ❑ មនុស្សគ្រប់គ្នាដែលអាចបំពេញកិច្ចការរបស់ខ្លួនពីផ្ទះ ត្រូវបានណែនាំឱ្យធ្វើដូច្នោះ។ ដំណើរការការងារត្រូវបានកែទម្រង់ឡើងវិញទៅតាមកម្រិតដែលអាចអនុវត្តបាន ដើម្បីបង្កើនឱកាសសម្រាប់ឱ្យបុគ្គលិកធ្វើការងារពីផ្ទះ។
- ❑ បុគ្គលិកងាយរងគ្រោះ (អ្នកដែលមានអាយុលើ 65 ឆ្នាំ អ្នកដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃ) ត្រូវបានកំណត់ឱ្យធ្វើការងារដែលអាចធ្វើបានពីផ្ទះ នៅពេលណាដែលអាចធ្វើទៅបាន។
- ❑ បុគ្គលិកទាំងអស់ត្រូវបានណែនាំមិនឱ្យមកធ្វើការ ឬ ចូលក្នុងបរិវេណ បើសិនជាឈឺនិងត្រូវអនុវត្តតាមការណែនាំរបស់ DPH សម្រាប់ការធ្វើចត្តាឡីស័ក (ដាក់ខ្លួនឯងឱ្យនៅដាច់ដោយឡែក) បើសិនជាអាចអនុវត្តបាន។
- ❑ ការពិនិត្យរោគសញ្ញាច្រកចូល ត្រូវតែអនុវត្តគ្រប់បុគ្គលិក/អ្នកទស្សនាទាំងអស់ដែលចូលក្នុងបរិវេណ។ ការពិនិត្យនេះត្រូវតែឆែកមើលលើស្ថានភាពពាក់ព័ន្ធនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងគ្រុនក្តៅឬគ្រុនរងា និងថាតើបុគ្គលនោះកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឱ្យនៅដាច់ដោយឡែក ឬ ការធ្វើចត្តាឡីស័ក (ដាក់ឱ្យដាច់ពីគេ) នាពេលបច្ចុប្បន្នឬទេ ដោយអនុលោមតាមការណែនាំនៃ ការត្រួតពិនិត្យការចូលរបស់DPH។ ការត្រួតពិនិត្យទាំងនេះអាចធ្វើទៅបានដោយរាល់ពេលដែលបុគ្គលិកមកដល់ឬតាមរយៈវិធីសាស្ត្រជំនួសដូចជាការត្រួតពិនិត្យតាមអនឡាញដោយប្រើប្រព័ន្ធប្រតិបត្តិ ឬតាមរយៈផ្លាកសញ្ញាដែលមានបិទនៅច្រកចូលនៃបរិវេណ ដែលបញ្ជាក់ថាបុគ្គលិកដែលមានរោគសញ្ញាទាំងនេះមិនត្រូវចូលក្នុងបរិវេណឡើយ។ ការត្រួតពិ និត្យសីតុណ្ហភាពក៏គួរតែត្រូវបានធ្វើនៅកន្លែងការងារដែរប្រសិនបើអាច។
  - ការត្រួតពិនិត្យបញ្ជាក់ថាអវិជ្ជមាន (ស្អាត) ។ ប្រសិនបើមនុស្សនោះមិនមានរោគសញ្ញានិងមិនមានទំនាក់ទំនងជាមួយករណីដែលត្រូវបានបញ្ជាក់ថាមានជំងឺ**COVID-19** ក្នុងរយៈពេល ១៤ ថ្ងៃចុងក្រោយទេនោះ ពួកគេអាចត្រូវបានអនុញ្ញាតដើម្បីចូលទីតាំង និងចូលរួមនៅថ្ងៃនោះបាន។
  - ការត្រួតពិនិត្យបញ្ជាក់ថាវិជ្ជមាន (មិនស្អាត)៖
    - ប្រសិនបើមនុស្សនោះមានទំនាក់ទំនងជាមួយករណីដែលត្រូវបានបញ្ជាក់ថាមានជំងឺ**COVID-19** ក្នុងរយៈពេល ១៤ ថ្ងៃចុងក្រោយ ឬកំពុងស្ថិតនៅក្រោមការបញ្ជាឱ្យធ្វើចត្តាឡីស័ក (ការដាក់ឱ្យនៅដាច់ដោយឡែក) ពួកគេមិនអាចចូលបានទេ ហើយត្រូវតែបញ្ជូនទៅផ្ទះវិញភ្លាមៗ ដើម្បីធ្វើចត្តាឡីស័កនៅផ្ទះ។ ដោយត្រូវផ្តល់ការណែនាំនៃការធ្វើចត្តាឡីស័ក (នៅដាច់ដោយឡែក)ដល់ពួកគេ ដែលមាននៅលើគេហទំព័រ ph.lacounty.gov/ covidquarantine។
    - ប្រសិនបើមនុស្សនោះបង្ហាញរោគសញ្ញាដែលត្រូវបានកំណត់សម្គាល់ដូចខាងលើ ឬកំពុងស្ថិតនៅក្រោមការបញ្ជាឱ្យធ្វើចត្តាឡីស័ក (ការដាក់ឱ្យនៅដាច់ដោយឡែក) គេមិនអាចចូលបានទេហើយត្រូវតែបញ្ជូនទៅផ្ទះវិញភ្លាមៗដើម្បីធ្វើចត្តាឡីស័កនៅផ្ទះ។ ដោយត្រូវផ្តល់ការណែនាំនៃការធ្វើចត្តាឡីស័ក (នៅដាច់ដោយឡែក)ដល់ពួកគេ ដែលមាននៅលើគេហទំព័រ ph.lacounty.gov/covidisolation ។
- ❑ ព័ត៌មានអំពីអត្ថប្រយោជន៍នៃការឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាលដែលបុគ្គលិកអាចនឹងមានសិទ្ធិទទួល ដែលនឹងធ្វើឱ្យវាកាន់តែមានភាពងាយស្រួលផ្នែកហិរញ្ញវត្ថុក្នុងការស្ថិតនៅផ្ទះ ត្រូវបានចែករំលែកដល់បុគ្គលិកទាំងអស់។ មើលព័ត៌មានបន្ថែមស្តីពី កម្មវិធីរដ្ឋាភិបាលដែលគាំទ្រការសុំច្បាប់ឈប់សម្រាកឈឺ និងសំណងបុគ្គលិកសម្រាប់ជំងឺ **COVID-19** ដោយរាប់បញ្ចូលទាំងសិទ្ធិសុំច្បាប់ឈប់សម្រាកឈឺរបស់បុគ្គលិកក្រោម ច្បាប់ស្តីពីការឆ្លើយតបនឹងមេរោគកូរ៉ូណាដោយលើកគ្រួសារជាអាទិភាព **(Families First Coronavirus Response Act)** និងសិទ្ធិរបស់បុគ្គលិកដើម្បីទទួលអត្ថប្រយោជន៍សំណងបុគ្គលិក និងការសន្និដ្ឋាននៃភាពទាក់ទងនឹងការងាររបស់ជំងឺ **COVID-**19 ដោយអនុលោមតាម បទបញ្ជាប្រតិបត្តិលេខ **N-**62-20 របស់អភិបាលរដ្ឋ។
- ❑ បន្ទាប់ពីទទួលព័ត៌មានថាមានបុគ្គលិក អ្នកម៉ៅការឯកជន និងបុគ្គលិកបណ្តោះអាសន្នម្នាក់ ឬច្រើននាក់ធ្វើតេស្តវិជ្ជមាន ឬមានរោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 (ករណី) និយោជកមានគម្រោងឬពិធីការដើម្បីឱ្យករណីទាំងនោះដាក់ខ្លួនឱ្យនៅដាច់ដោយឡែកនៅផ្ទះ និងតម្រូវឱ្យមានការនៅដាច់ពីគេដោយខ្លួនឯងភ្លាមៗសម្រាប់បុគ្គលិកដែលមានការប៉ះពាល់ជាមួយករណីនៅកន្លែងធ្វើការ។ គម្រោងរបស់និយោជកគួរតែពិចារណាពីពិធីការសម្រាប់បុគ្គលិកដែលបាននៅដាច់ពីគេទាំងអស់ ដើម្បីអាចទទួលបាន ឬធ្វើតេស្តរកជំងឺ COVID-19 ដើម្បីកំណត់ថាតើមានការប៉ះពាល់នៅកន្លែងធ្វើការបន្ថែមទៀតឬក៏អត់ ដែលអាចតម្រូវឱ្យមានវិធានការណ៍គ្រប់គ្រងជំងឺ COVID-19 បន្ថែម។ មើលការណែនាំសុខភាពសាធារណៈស្តីពី ការឆ្លើយតបនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ។
- ❑ នៅក្នុងករណីដែលរកឃើញមាន 3 ករណីឬច្រើនជាងនេះនៅកន្លែងធ្វើការក្នុងរយៈពេល 14 ថ្ងៃ នោះនិយោជកត្រូវតែរាយការណ៍ពីការចម្លងជាចង្កោមនេះទៅនាយកដ្ឋានសុខភាពសាធារណៈតាមរយៈលេខ (888) 397-3993 ឬ (213) 240-7821 ឬតាមអនឡាញនៅ www.redcap.link/covidreport។ បើសិនជាចង្កោមត្រូវបានរកឃើញនៅកន្លែងធ្វើការ នាយកដ្ឋានសុខភាពសាធារណៈ នឹងចាប់ផ្តើមការឆ្លើយតបចំពោះការឆ្លងជាក្រុម ដែលរួមមានដូចជាការផ្តល់ការណែនាំ និងអនុសាសន៍អំពីការគ្រប់គ្រងការឆ្លងជំងឺ ការគាំទ្របច្ចេកទេស និងវិធានការណ៍គ្រប់គ្រងដែលជាក់លាក់សម្រាប់ទីកន្លែង។ អ្នកគ្រប់គ្រងករណីសុខភាពសាធារណៈ នឹងត្រូវបានចាត់តាំងដើម្បីធ្វើការស៊ើបអង្កេតការឆ្លងជាក្រុមដើម្បីដឹកនាំការឆ្លើយតបនៅទីកន្លែង។
- ❑ បុគ្គលិកដែលមានការប៉ះពាល់ជាមួយអ្នកដទៃនឹងទទួលបានរបាំងមុខ ដោយឥតគិតថ្លៃ ដែលអាចពាក់សមទៅនឹងច្រមុះ និងមាត់ ។ បុគ្គលិកត្រូវពាក់របាំងមុខគ្រប់ពេលវេលា ក្នុងអំឡុងថ្ងៃធ្វើការ នៅពេលប៉ះពាល់ ឬទំនងជាប៉ះពាល់

ជាមួយអ្នកដទៃ។ បុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាពួកគេមិនគួរពាក់របាំងមុខ ត្រូវតែពាក់ឧបករណ៍ការពារដែលមិនរាំងស្ទះផ្សេងទៀត ដូចជាសន្ទះបាំងមុខដែលមានក្រណាត់គ្របនៅគែមខាងក្រោម ដើម្បីអនុលោមតាម[បទបញ្ញារបស់រដ្ឋ] ដរាបណាល័ក្ខខ័ណ្ឌសុខភាពរបស់ពួកគេអនុញ្ញាត។ យកល្អគួរប្រើក្រណាត់គ្របដែលមានទម្រង់រឹតតឹងនៅខាងក្រោមចង្កា។ ម៉ាស់ដែលមានវ៉ាល់តែមួយផ្លូវគឺមិនអាចប្រើបានឡើយ។

- ❑ បុគ្គលិកទាំងអស់ត្រូវតែពាក់==របាំងមុខ==នៅគ្រប់ពេលវេលា លើកលែងតែពេលធ្វើការម្នាក់ឯងនៅក្នុងការិយាល័យឯកជន ដោយបិទទ្វារជិត ឬនៅពេលបរិភោគ ឬផឹក។ ល័ក្ខខ័ណ្ឌតម្រូវនេះបដិសេធចោលនូវករណីលើកលែងពីមុនសម្រាប់បុគ្គលិកដែលធ្វើការនៅក្នុងបន្ទប់តូចដោយមានរបាំងខ័ណ្ឌរឹងមាំហួសពីកម្ពស់ឈររបស់បុគ្គលិក។
- ❑ ដើម្បីធ្វើឱ្យប្រាកដថាម៉ាស់ត្រូវបានពាក់យ៉ាងខ្ជាប់ខ្ជួននិងត្រឹមត្រូវ បុគ្គលិកត្រូវបានហាមឃាត់មិនឱ្យបរិភោគ ឬផឹក លើកលែងតែក្នុងអំឡុងពេលការសម្រាករបស់ពួកគេ នៅពេលដែលពួកគេអាចដោះម៉ាស់របស់ខ្លួន និងរក្សាគម្លាតរាងកាយពីអ្នកដទៃបានដោយសុវត្ថិភាព។ នៅគ្រប់ពេលវេលាទាំងអស់នៅពេលបរិភោគ ឬផឹក បុគ្គលិកត្រូវតែរក្សាគម្លាតយ៉ាងតិច 6 ហ្វីតពីអ្នកដទៃ។ នៅពេលបរិភោគ ឬផឹក វាជាការប្រសើរដែលត្រូវធ្វើដូច្នោះនៅខាងក្រៅអគារ និងឆ្ងាយពីអ្នកដទៃ បើសិនជាអាចធ្វើបាន។ ការបរិភោគ ឬការផឹកនៅបន្ទប់តូច ឬស្ថានីយការងារគឺប្រសើរជាងការបរិភោគនៅក្នុងបន្ទប់សម្រាក បើសិនជាការបរិភោគនៅបន្ទប់តូច ឬស្ថានីយការងារផ្តល់នូវគម្លាតកាន់តែធំ និងរបាំងរវាងបុគ្គលិក។
- ❑ បុគ្គលិកត្រូវបានណែនាំឱ្យបោកគក់ ==បើអាចធ្វើបាន== ឬផ្លាស់ប្តូរ==របាំងមុខ==របស់ខ្លួនជារៀងរាល់ថ្ងៃ។
- ❑ ចំនួនមនុស្សត្រូវបានកាត់បន្ថយ ហើយគម្លាតរវាងបុគ្គលិក ត្រូវបានបង្កើនជាអតិបរមានៅក្នុងបន្ទប់ ឬកន្លែងនានាដែលបុគ្គលិកប្រើសម្រាប់បរិភោគអាហារនិង/ឬសម្រាក។ ចំណុចនេះត្រូវបានសម្រេចដោយ៖
    - ○ បិទស្លាកសញ្ញាកំណត់ចំនួនមនុស្សអតិបរមាដែលអនុញ្ញាតឱ្យមានការរក្សាគម្លាតយ៉ាងតិចប្រាំមួយហ្វីតរវាងបុគ្គលនៅក្នុងបន្ទប់ ឬកន្លែងដែលប្រើសម្រាប់ការសម្រាក និង
    - ○ ឆ្លាស់ម៉ោងសម្រាក ឬម៉ោងបរិភោគអាហារ ដើម្បីកាត់បន្ថយចំនួនមនុស្សនៅក្នុងបន្ទប់ ឬទីកន្លែងដែលប្រើសម្រាប់ការបរិភោគអាហារ និងសម្រាក និង
    - ○ ដាក់តុឃ្លាតពីគ្នាយ៉ាងតិច ==8ហ្វីត== និងធានាបាននូវគម្លាតប្រាំមួយហ្វីតរវាងកន្លែងអង្គុយ ដោយដកកៅអី ឬបិទបង់ស្អិតលើកៅអីដើម្បីកាត់បន្ថយចំនួនមនុស្ស ដាក់គ្រឿងសម្គាល់លើកម្រាលឥដ្ឋ ដើម្បីធានាបាននូវការរក្សាគម្លាត និងរៀបចំកន្លែងអង្គុយតាមរបៀបមួយដែលកាត់បន្ថយការប៉ះពាល់ទល់មុខគ្នា។ ការប្រើប្រាស់របាំងខណ្ឌចែក ត្រូវបានលើកទឹកចិត្តដើម្បីទប់ស្កាត់ការរីករាលដាលបន្ថែមទៀត ប៉ុន្តែមិនគួរចាត់ទុកថាជាវិធីជំនួសឱ្យការកាត់បន្ថយចំនួនមនុស្ស និងការរក្សាគម្លាតរាងកាយឡើយ។
- ❑ នៅកន្លែងដែលអាចធ្វើបាន ទីកន្លែងសម្រាកខាងក្រៅអគារត្រូវបានបង្កើតឡើង និងត្រូវបានបំពាក់ជាមួយនឹងគម្របម្លប់ និងកន្លែងអង្គុយដែលអនុញ្ញាតឱ្យបុគ្គលិករក្សាគម្លាតរាងកាយ 6 ហ្វីតពីអ្នកដទៃនៅគ្រប់ពេលវេលា។
- ❑ តុ ឬកន្លែងការងារសម្រាប់បុគ្គលទាំងអស់ត្រូវបានបំបែកពីគ្នាយ៉ាងតិច 6ហ្វីត។
- ❑ បន្ទប់សម្រាក បន្ទប់ទឹក និងទីកន្លែងទូទៅផ្សេងទៀត កំពុងត្រូវបានសម្លាប់មេរោគជារៀងរាល់ម៉ោងទៅតាមកាលវិភាគដូចខាងក្រោម៖
    - ○ បន្ទប់សម្រាក៖ ____________________
    - ○ បន្ទប់ទឹក៖ ____________________
    - ○ ផ្សេងទៀត៖ ____________________
- ❑ សារធាតុសម្លាប់មេរោគ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធគឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាងក្រោម៖

  ____________________________________________
- ❑ ទឹកអនាម័យលាងដៃដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាងក្រោម៖

  ____________________________________________
- ❑ សាប៊ូ និងទឹកគឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាងក្រោម៖

  ____________________________________________
- ❑ បុគ្គលិកត្រូវបានអនុញ្ញាតឱ្យសម្រាកឱ្យបានញឹកញាប់ដើម្បីលាងដៃរបស់ខ្លួន។
- ❑ កម្មករនីមួយៗ ត្រូវបានកំណត់ឧបករណ៍ផ្ទាល់ខ្លួន បរិក្ខារ និងលំហធ្វើការដែលបានកំណត់។ នៅគ្រប់ពេលដែលអាចធ្វើបាន ការប្រើប្រាស់វត្ថុដែលមានការប៉ះពាល់រួមគ្នា (ឧទាហរណ៍ដូចជា ទូរស័ព្ទ ថេប្លិត កុំព្យូទ័រយួរដៃ តុ ប៊ិច ។ល។) ត្រូវតែកាត់បន្ថយ ឬជៀសវាងតែម្តង។
- ❑ គោលការណ៍ទាំងអស់ដែលបានពិពណ៌នានៅក្នុងបញ្ជីត្រួតពិនិត្យនេះក្រៅពីគោលការណ៍ដែលទាក់ទងនឹងល័ក្ខខ័ណ្ឌ

ការងារ ត្រូវបានអនុវត្តចំពោះបុគ្គលិកផ្នែកដឹកជញ្ជូន និងក្រុមហ៊ុនផ្សេងៗទៀតដែលអាចស្ថិតនៅទីតាំងនោះក្នុងនាមជាភាគីទីបី។

- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកទាំងអស់។
- ❑ ជម្រើសផ្សេង—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

______________________________________________________________________________

## B. វិធានការណ៍ដើម្បីធានាបាននូវការរក្សាគម្លាតរាងកាយ (គូសធីកទាំងអស់ដែលអនុវត្ត)

- ❑ កំណត់ចំនួនមនុស្សនៅក្នុងទីកន្លែងក្នុងពេលវេលាណាមួយ ដែលអនុញ្ញាតឱ្យអតិថិជន/ភ្ញៀវ និងបុគ្គលិករក្សាគម្លាតយ៉ាងតិចប្រាំមួយហ្វីតពីគ្នាបានយ៉ាងងាយស្រួលនៅគ្រប់ពេលវេលាដែលអាចអនុវត្តបាន។
- ❑ ចំនួនមនុស្សអតិបរមាដែលបានអនុញ្ញាតនៅក្នុងទីកន្លែងដើម្បីគោរពតាមល័ក្ខខ័ណ្ឌតម្រូវនៃការរក្សាគម្លាតរាងកាយ៖ _____
- ❑ ដាក់ឱ្យបុគ្គលិកម្នាក់ប្រចាំការនៅទ្វារចូល ដើម្បីប្រាកដថាមិនលើសចំនួនមនុស្សអតិបរមានៅក្នុងអគារ។
    - ○ មន្ទីរ ឬទីកន្លែងធ្វើការត្រួតពិនិត្យច្រកចូលទាំងអស់ដើម្បីតាមដាននិងដាក់កំណត់ចំនួនមនុស្ស។ នៅពេលដែលអាចធ្វើបាន ផ្តល់ច្រកចូលតែមួយដែលបានកំណត់ច្បាស់លាស់ និងច្រកចេញដាច់ដោយឡែកដើម្បីជួយអនុវត្តការរក្សាគម្លាតរាងកាយ។
    - ○ ត្រៀមរៀបចំឱ្យអតិថិជន/ភ្ញៀវតម្រង់ជួរនៅខាងក្រៅ ខណៈដែលនៅតែអនុវត្តការរក្សាគម្លាតរាងកាយ រាប់បញ្ចូលទាំងការប្រើប្រាស់តម្រុយជារូបភាព។ បើសិនជាចាំបាច់ បុគ្គលិកម្នាក់ (ឬច្រើននាក់បើសិនជាមានច្រកចូលច្រើនជាងមួយ) ដែលពាក់របាំងមុខអាចត្រូវបានចាត់ឱ្យប្រចាំការនៅជិតទ្វារ ប៉ុន្តែមានគម្លាតយ៉ាងតិច 6 ហ្វីតពីអតិថិជនដែលជិតបំផុត ដើម្បីតាមដានចំនួនអតិថិជន និងដើម្បីណែនាំឱ្យអតិថិជន/ភ្ញៀវតម្រង់ជួរដោយឃ្លាតពីគ្នាប្រាំមួយហ្វីតនៅខាងក្រៅច្រកចូល បើសិនជាទីកន្លែងបានឈានដល់ដែនកំណត់ចំនួនអតិថិជនរបស់ខ្លួន។
    - ○ បុគ្គលិកសន្តិសុខនៅប្រចាំការនឹងទីកន្លែង ធ្វើការរំលឹក និងលើកទឹកចិត្តអតិថិជន/ភ្ញៀវ និងសាធារណជនយ៉ាងសកម្មឱ្យអនុវត្តតាមបទដ្ឋាននៃការរក្សាគម្លាតរាងកាយ ល័ក្ខខ័ណ្ឌតម្រូវឱ្យពាក់របាំងមុខ និងរំលឹកដល់អតិថិជន និងភ្ញៀវថាមិនអនុញ្ញាតឱ្យមានការបរិភោគ និងផឹកនៅលើទីកន្លែងឡើយ។
- ❑ បើសិនជាអាចអនុវត្តបាន កន្លែងអង្គុយត្រូវតែរៀបចំឡើងវិញ ដើម្បីធានាថាអ្នកចូលរួម/ភ្ញៀវទាំងអស់អាចរក្សាគម្លាតរាងកាយយ៉ាងតិច 6 ហ្វីតរវាងខ្លួនពួកគេ និងអ្នកដទៃដែលមិនមែនជាសមាជិកគ្រួសាររបស់ខ្លួន។
- ❑ ជម្រើសផ្សេង-ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

______________________________________________________________________________

## C. វិធានការណ៍ដើម្បីរក្សាឱ្យមនុស្សស្ថិតនៅឃ្លាតពីគ្នាយ៉ាងតិចប្រាំមួយហ្វីត (គូសធីកទាំងអស់ដែលអនុវត្ត)

- ❑ ការដាក់ស្លាកសញ្ញានៅខាងក្រៅបរិវេណដើម្បីរំលឹកឱ្យមានការរក្សាគម្លាតពីគ្នាយ៉ាងតិច 6ហ្វីត រាប់ទាំងពេល តម្រង់ជួរ។
- ❑ ការបិទបង់ស្អិត ឬគ្រឿងសម្គាល់ផ្សេងទៀតដែលមានគម្លាតយ៉ាងតិចប្រាំមួយហ្វីតពីគ្នានៅទីកន្លែងតម្រង់ជួររបស់អតិថិជនខាងក្នុងមន្ទីរ ឬទីកន្លែង និងនៅលើផ្លូវដើរនៃច្រកចូលសាធារណៈដោយមានសញ្ញាណែនាំឱ្យអតិថិជនប្រើប្រាស់គ្រឿងសម្គាល់ដើម្បីរក្សាគម្លាត។
- ❑ បំបែកតំបន់ស្តុកទុកពីតំបន់ដឹកជញ្ជូនដើម្បីទប់ស្កាត់កុំឱ្យអតិថិជន/ភ្ញៀវប្រមូលផ្តុំ បើសិនជាអាចអនុវត្តបាន។
- ❑ បុគ្គលិក/ភ្ញៀវទាំងអស់ត្រូវបានណែនាំឱ្យរក្សាគម្លាតយ៉ាងតិចប្រាំមួយហ្វីតពីអតិថិជន និងពីបុគ្គលិកដូចគ្នា និងពីមនុស្សដទៃមិនមែនជាគ្រួសាររបស់ខ្លួន លើកលែងតែបុគ្គលិកអាចមកជិតមួយភ្លែតនៅពេលចាំបាច់ដើម្បីទទួលយកការបង់ប្រាក់ ដឹកជញ្ជូនទំនិញឬសេវាកម្ម ឬនៅពេលចាំបាច់។
- ❑ ផ្តល់ជូនច្រកចូល និងច្រកចេញដាច់ដោយឡែកដែលបានកំណត់យ៉ាងច្បាស់ បើសិនជាអាចធ្វើបាននិងសមស្របសម្រាប់ទីកន្លែង ដើម្បីជួយរក្សាគម្លាតរាងកាយ និងគាំទ្រការគ្រប់គ្រងហ្វូងមនុស្ស។ នៅគ្រប់ពេលដែលអាចធ្វើបាន គេគួរទុកទ្វារឱ្យចំហ បើសិនជាវាមិនបិទបើកដោយស្វ័យប្រវត្តិ។
- ❑ បើសិនជាអាចអនុវត្តបាន ចូរចាប់ផ្តើមច្រកដើរ ឬផ្លូវដើរមួយផ្លូវដើម្បីគាំទ្រការរក្សាគម្លាតរាងកាយ។
- ❑ បើអាចអនុវត្តបាន ចំណុះជណ្តើរយន្តត្រូវបានដាក់កម្រិតត្រឹម 4 នាក់ ឬតិចជាងនេះនៅក្នុងពេលម្តងសម្រាប់ជណ្តើរយន្តទាំងឡាយដែលមិនអនុញ្ញាតឱ្យមានគម្លាតរាងកាយ 6 ហ្វីតរវាងអ្នកជិះ។ អ្នកជិះទាំងអស់ត្រូវបានតម្រូវឱ្យពាក់របាំងមុខ។ ពិចារណាពីទំហំជណ្តើរយន្ត ចំនួនជាន់របស់អគារ និងចំនួនបុគ្គលិកប្រចាំថ្ងៃដើម្បីបង្កើតគោលការណ៍ណែនាំអំពីការរក្សាគម្លាតរាងកាយដែលសមស្របសម្រាប់អ្នកជិះជណ្តើរយន្ត។
- ❑ បើអាចអនុវត្តបាន ជណ្តើរត្រូវបានបើកសម្រាប់ចរាចរណ៍ "ឡើង" ឬ "ចុះ" ដោយមានការសម្អាតជណ្តើរច្រើនជាង

មុន។

- [ ] ជម្រើសផ្សេង—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖ ______________________________

## D. វិធានការណ៍ដើម្បីលើកកម្ពស់ការគ្រប់គ្រងការឆ្លងជំងឺ

- [ ] ភ្ញៀវដែលមកដល់អាជីវកម្មត្រូវបានរំលឹកពីល័ក្ខខ័ណ្ឌតម្រូវឱ្យពាក់របាំងមុខនៅគ្រប់ពេលវេលា ខណៈពេលនៅក្នុងទីកន្លែង ឬលើទីធ្លារបស់ទីកន្លែង។ នេះអនុវត្តទៅលើមនុស្សធំទាំងអស់ និងកុមារដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ។ បុគ្គលដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ពួកគេថា ពួកគេមិនគួរពាក់ម៉ាស់បិទមុខត្រូវតែមានជម្រើសពាក់ឧបករណ៍ផ្សេងទៀតដែលមិនរឹតត្បិតដូចជារបាំងមុខដែលមានក្រវ៉ាត់នៅលើគែមខាងក្រោមដោយអនុលោមតាមសេចក្តីណែនាំរបស់រដ្ឋ([State directive](#))ដរាបណាពួកគេត្រូវល័ក្ខខ័ណ្ឌដែលអនុញ្ញាតនេះ។ ក្រណាត់ដែលមានទម្រង់សមនៅក្រោមចង្កាគួរត្រូវយកមកប្រើ ។ របាំងដែលមានស្រទាប់មួយជាន់ មិនត្រូវប្រើទេ។ ដើម្បីគាំទ្រសុវត្ថិភាពរបស់បុគ្គលិកអ្នក និងភ្ញៀវផ្សេងទៀត គេគួរផ្តល់របាំងមុខដល់ភ្ញៀវដែលមកដល់ដោយមិនមានវា។
- [ ] [ការពិនិត្យរោគសញ្ញាច្រកចូល](#) ត្រូវបានធ្វើឡើងមុនពេលភ្ញៀវ ដៃគូសហការផ្សេងៗ ឬអ្នកផ្តល់សេវាអាចចូលក្នុងទីបរិវេណ ដោយអនុលោមតាម[ការណែនាំនៃ ការត្រួតពិនិត្យការចូលរបស់ DPH](#) ។ ការត្រួតពិនិត្យទាំងនេះអាចធ្វើទៅបានដោយរាល់ពេលដែលបុគ្គលិកមកដល់ឬតាមរយៈវិធីសាស្ត្រជំនួសដូចជាការត្រួតពិនិត្យតាមអនឡាញដោយប្រើប្រព័ន្ធប្រតិបត្តិ ឬតាមរយៈផ្លាកសញ្ញាដែលមានបិទនៅច្រកចូលនៃបរិវេណ ដែលបញ្ជាក់ថា បុគ្គលិកដែលមានរោគសញ្ញាទាំងនេះមិនត្រូវចូលក្នុងបរិវេណឡើយ។ ការត្រួតពិនិត្យសីតុណ្ហភាពក៏គួរតែត្រូវបានធ្វើនៅកន្លែងការងារដែរប្រសិនបើអាច។
    - ការត្រួតពិនិត្យបញ្ជាក់ថាអវិជ្ជមាន (ស្អាត) ។ ប្រសិនបើមនុស្សនោះមិនមានរោគសញ្ញានិងមិនមានទំនាក់ទំនងជាមួយករណីដែលត្រូវបានបញ្ជាក់ថាមានជំងឺ **COVID-19** ក្នុងរយៈពេល ១៤ ថ្ងៃចុងក្រោយទេនោះ ពួកគេអាចត្រូវបានអនុញ្ញាតដើម្បីចូលទីតាំង និងធ្វើការនៅថ្ងៃនោះបាន។
    - ការត្រួតពិនិត្យបញ្ជាក់ថាវិជ្ជមាន (មិនស្អាត)៖
        - ប្រសិនបើមនុស្សនោះមានទំនាក់ទំនងជាមួយករណីដែលត្រូវបានបញ្ជាក់ថាមានជំងឺ **COVID-19** ក្នុងរយៈពេល ១៤ ថ្ងៃចុងក្រោយ ឬកំពុងស្ថិតនៅក្រោមការបញ្ជាឱ្យធ្វើចត្តាឡីស័ក (ការដាក់ឱ្យនៅដាច់ដោយឡែក) ពួកគេមិនអាចចូលបានទេ ហើយត្រូវតែបញ្ជូនទៅផ្ទះវិញភ្លាមៗ ដើម្បីធ្វើចត្តាឡីស័កនៅផ្ទះ។ ដោយត្រូវផ្តល់ការណែនាំនៃការធ្វើចត្តាឡីស័ក (នៅដាច់ដោយឡែក)ដល់ពួកគេ ដែលមាននៅលើគេហទំព័រ [ph.lacounty.gov/ covidquarantine](#) ។
        - ប្រសិនបើមនុស្សនោះបង្ហាញរោគសញ្ញាដែលត្រូវបានកំណត់សម្គាល់ដូចខាងលើ ឬកំពុងស្ថិតនៅក្រោមការបញ្ជាឱ្យធ្វើចត្តាឡីស័ក (ការដាក់ឱ្យនៅដាច់ដោយឡែក) គេមិនអាចចូលបានទេហើយត្រូវតែបញ្ជូនទៅផ្ទះវិញភ្លាមៗដើម្បីធ្វើចត្តាឡីស័កនៅផ្ទះ។ ដោយត្រូវផ្តល់ការណែនាំនៃការធ្វើចត្តាឡីស័ក (នៅដាច់ដោយឡែក)ដល់ពួកគេ ដែលមាននៅលើគេហទំព័រ [ph.lacounty.gov/covidisolation](#) ។
- [ ] ប្រព័ន្ធ HVAC គឺស្ថិតក្នុងសភាពដំណើរការល្អធម្មតា ដល់កម្រិតជាអតិបរមា ដែលអាចធ្វើឱ្យខ្យល់ចេញចូលត្រូវបានបង្កើនឡើង។ ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់មានប្រសិទ្ធភាពខ្ពស់ចល័ត ធ្វើឱ្យប្រសើរឡើងនូវតម្រងខ្យល់របស់អគារឱ្យមានប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែផ្សេងទៀតដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅ និងខ្យល់ចេញចូលនៅក្នុងការិយាល័យ និងទីកន្លែងផ្សេងៗទៀត។ មើលការណែនាំសុខភាពសាធារណៈអំពីរបៀបធ្វើឱ្យការចេញចូលខ្យល់ប្រសើរឡើង។
- [ ] ប្រព័ន្ធបង់ប្រាក់ដោយមិនបាច់ប៉ះ គឺមានសម្រាប់ឱ្យប្រើ ឬបើមិនអាចធ្វើបាន ប្រព័ន្ធបង់ប្រាក់ត្រូវបានធ្វើអនាម័យជារៀងរាល់ម៉ោង។ ពិពណ៌នា៖ ______________________________
- [ ] ទីកន្លែងរួមទៅ និងទីកន្លែងដែលមានចរាចរណ៍ខ្ពស់ ក៏ដូចជាវត្ថុដែលបានប៉ះពាល់ញឹកញាប់ (ឧ. បង្កាន់ដៃ ផ្នែកបញ្ជានៃជណ្តើរយន្ត ដៃទ្វារ ឬដៃកាន់ ម៉ាស៊ីនអានកាតឥណទាន ប៊ូតុងជណ្តើរយន្ត បង្កាន់ដៃជណ្តើរយន្តជើង ។ល។) ត្រូវបានសម្លាប់មេរោគជារៀងរាល់ម៉ោងក្នុងអំឡុងម៉ោងធ្វើការ ដោយប្រើផលិតផលសម្លាប់មេរោគដែលបានអនុម័តដោយ EPA ដោយអនុវត្តតាមការណែនាំរបស់ក្រុមហ៊ុនផលិតសម្រាប់ការប្រើប្រាស់។
- [ ] ទីកន្លែងការងារ និងអគារទាំងមូលត្រូវបានសម្អាតយ៉ាងតិចជាប្រចាំថ្ងៃ ដោយបន្ទប់ទឹក និងតំបន់/វត្ថុដែលបានប៉ះញឹកញាប់ ត្រូវបានសម្អាតជារៀងរាល់ម៉ោង។ ម៉ោងនៃមជ្ឈមណ្ឌលទិញទំនិញត្រូវបានលៃតម្រូវ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការសម្អាតស៊ីជម្រៅជាប្រចាំ និងការដាក់ស្តុកផលិតផល។
- [ ] បន្ទប់ទឹកសាធារណៈត្រូវបានធ្វើអនាម័យជារៀងរាល់ម៉ោងដោយប្រើផលិតផលសម្លាប់មេរោគដែលបានអនុម័តដោយ EPA ដោយអនុវត្តតាមការណែនាំរបស់ក្រុមហ៊ុនផលិតសម្រាប់ការប្រើប្រាស់ តាមកាលវិភាគដូចខាងក្រោម៖

______________________________________________

- ❑ ទឹកបាញ់សម្រាប់ផឹកសាធារណៈ: ត្រូវបានបិទ និងមានស្លាកសញ្ញាជម្រាបជូនអតិថិជនថាពួកគេមិនអាចប្រើវាបានទេ។
- ❑ អតិថិជន/ភ្ញៀវដែលមកដល់ទីកន្លែងជាមួយកូនៗត្រូវតែប្រាកដថាកូនរបស់ពួកគេស្ថិតនៅជិតឪពុកម្ដាយ ចៀសវាងការប៉ះអ្នកដទៃ ឬវត្ថុណាមួយដែលមិនមែនជារបស់ពួកគេ និងត្រូវពាក់ម៉ាស់បើសិនជាដល់អាយុ។
- ❑ អតិថិជន/ភ្ញៀវអាចប្រើប្រាស់ផលិតផលរក្សាអនាម័យសមស្រប រួមមានទឹកអនាម័យលាងដៃ ក្រដាសជូតមាត់ និងធុងសម្រាម។
- ❑ ផ្តល់ប្រព័ន្ធបង់ប្រាក់ដែលមិនមានការប៉ះ ឬបើមិនអាចធ្វើបាន ធ្វើអនាម័យប្រព័ន្ធបង់ប្រាក់ជាប្រចាំ។ ព័ត៌មាន៖

______________________________________________

- ❑ ជម្រើសផ្សេង-ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត (ឧ. ការផ្តល់ម៉ោងធ្វើការសម្រាប់តែជនចាស់ជរា)៖

______________________________________________

## E. វិធានការណ៍ដែលទាក់ទងជាមួយសាធារណជន (គូសធីកទាំងអស់ដែលអនុវត្តសម្រាប់ទីកន្លែង)

- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទាំងអស់ចូលក្នុងអគារ។
- ❑ ស្លាកសញ្ញា ត្រូវបានបិទផ្សាយនៅតាមច្រកចូលទាំងអស់មកកាន់មន្ទីរ ឬទីកន្លែងរំលឹកដល់ ភ្ញៀវទស្សនា ដៃគូសហការផ្សេងៗ អតិថិជន ឬអ្នកផ្តល់សេវា ដើម្បីរក្សាគម្លាតរាងកាយពីគ្នា6ហ្វីត ការចាំបាច់ដែលត្រូវពាក់របាំងមុខនៅគ្រប់ពេលវេលា សារៈសំខាន់នៃការលាងដៃជាប្រចាំ ឬការប្រើប្រាស់ទឹកអនាម័យលាងដៃ និងការចាំបាច់ដែលត្រូវនៅតែផ្ទះបើសិនជាពួកគេមានអារម្មណ៍ថាឈឺ ឬមានរោគសញ្ញានៃជំងឺ COVID-19។
- ❑ ស្លាកសញ្ញានៅក្នុងមន្ទីរ ឬទីកន្លែងទាំងមូល ដែលរំលឹកដល់អតិថិជនថាមិនអនុញ្ញាតឱ្យមានការបរិភោគ ឬការផឹកនៅលើកន្លែងឡើយ។
- ❑ ស្លាកសញ្ញានៅក្នុងមន្ទីរ ឬទីកន្លែងទាំងមូលចង្អុលបង្ហាញដល់អតិថិជនពីកន្លែងដើម្បីស្វែងរកឧបករណ៍បាញ់ទឹកអនាម័យលាងដៃដែលជិតបំផុត។
- ❑ ច្រកអនឡាញរបស់អាជីវកម្ម (គេហទំព័រ បណ្តាញសង្គម ។ល។) ផ្តល់ព័ត៌មានច្បាស់លាស់អំពីម៉ោងប្រតិបត្តិការ ការតម្រូវឱ្យប្រើរបាំងមុខ កំណត់ចំនួនអតិថិជន គោលការណ៍ផ្សេងៗដែលទាក់ទងនឹងការកំណត់ពេលណាត់ជួប ឬការកក់ទុកជាមុន ការបញ្ជាទិញជាមុន ការបង់ប្រាក់ជាមុន ការមកយកទំនិញនិង/ឬការដឹកជញ្ជូន និងបញ្ហាដែលពាក់ព័ន្ធផ្សេងៗទៀត។

## F. វិធានការណ៍សម្រាប់មន្ទីរ ឬទីកន្លែងដែលបើកទ្វារដល់សាធារណជន

- ❑ បន្ទប់ទឹកដែលជាធម្មតាបើកទ្វារដល់សាធារណជន ត្រូវបន្តបើកទ្វារដល់សាធារណជនដដែល។
- ❑ ក្រដាសជូតសម្លាប់មេរោគដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមាននៅជិតរទេះទិញឥវ៉ាន់ និងកន្ត្រកទិញឥវ៉ាន់ បើសិនជាអាចអនុវត្តបាន។
- ❑ បុគ្គលិកត្រូវបានចាត់តាំងឱ្យសម្លាប់មេរោគរទេះ និងកន្ត្រកជារៀងរាល់ម៉ោង បើសិនជាអាចអនុវត្តបាន។
- ❑ ទឹកអនាម័យលាងដៃ សាប៊ូនិងទឹក ឬសារធាតុសម្លាប់មេរោគដែលមានប្រសិទ្ធភាព គឺមានសម្រាប់សាធារណជននៅ ឬក្បែរច្រកចូលនៃទីកន្លែង នៅបញ្ជរគិតលុយ និងគ្រប់ទីកន្លែងផ្សេងទៀតនៅខាងក្នុងហាង ឬខាងក្រៅ ដែលមនុស្សមានការប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់។
- ❑ ការសម្លាប់មេរោគឧបករណ៍សម្រាប់បង់ប្រាក់ ប៊ិច ប៊ិចសម្រាប់ប្រើលើថាច់ជារៀងរាល់ម៉ោង។
- ❑ ការសម្លាប់មេរោគផ្ទៃដែលមានការប៉ះពាល់ច្រើនជារៀងរាល់ម៉ោង។

## G. វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

- ❑ សេវាកម្មដែលចាំបាច់ខ្លាំងសម្រាប់អតិថិជន/ភ្ញៀវត្រូវបានផ្តល់អាទិភាព។
- ❑ ប្រតិបត្តិការ ឬសេវាកម្មដែលអាចត្រូវបានផ្តល់ពីចម្ងាយ ត្រូវបានប្តូរទៅអនឡាញ។
- ❑ វិធានការណ៍ត្រូវបានអនុវត្តនៅតាមទីកន្លែងដើម្បីធានាបាននូវការទទួលបានទំនិញ និងសេវាកម្មសម្រាប់អតិថិជន/ភ្ញៀវដែលមានបញ្ហាក្នុងការផ្លាស់ទី និង/ឬដែលមានហានិភ័យខ្ពស់នៅទីសាធារណៈ។
- ❑ ជម្រើសផ្សេង- ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

វិធានការណ៍បន្ថែមទាំងឡាយដែលខុសពីខាងលើ គួរត្រូវបានរាយនៅលើទំព័រដាច់ដោយឡែក ដែលទីកន្លែងគួរភ្ជាប់ជាមួយឯកសារនេះ។

អ្នកអាចទាក់ទងបុគ្គលខាងក្រោមជាមួយសំណួរ ឬមតិអំពីពិធីការនេះ៖

ឈ្មោះទំនាក់ទំនងទីកន្លែង៖ ______________________

លេខទូរស័ព្ទ៖ ______________________

កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖ ______________________

ចូលនិវត្តន៍ - មិនមានប្រសិទ្ធភាពទេ